## មានកម្មវិធីផ្សេងទៀតផ្តល់ជំនួយជូន

ពតិមាននៅលើឯកសារបោះពុម្ពនេះត្រូវចំពោះតែកម្មវិធី OHP ក៏រឹតស្តង់ដាតែប៉ុណ្ណោះ ។ វាមិនត្រូវចំពោះគម្រោងគាំពារសុខភាពកុមារ, OHP ផ្លឹស ឬកម្មវិធីផ្តល់កិច្ចថែរក្សាសុខភាពផ្សេងទៀតនោះឡើយ ។ ដើម្បីចង់ដឹងថាតើអ្នក ឬមនុស្សផ្សេងទៀតនៅក្នុងសមាជិកគ្រួសារអ្នក គឺទទួលជំនួយពីកម្មវិធីផ្សេងទៀតបានដែរឬអត់ អ្នកត្រូវបំពេញពាក្យសុំ OHP ។

ដើម្បីស្នើសុំពាក្យសុំ OHP ចូរទូរស័ព្ទទៅលេខ 1-800-359-9517 (TTY 711) ឬក៏ទៅយកពីការិយាល័យសាខាក្រសួង DHS ណាមួយក្នុងតំបន់ដែលអ្នករស់នៅឬបំពេញពាក្យសុំតាមអ៊ីនធឺណែតឯ https://apps.state.or.us/mbs ។

Healthy Kids

**តើអ្នកមានកូនដែលត្រូវការកិច្ចថែរក្សាសុខភាពដែរទេ?**
រដ្ឋអូរីហ្គិនមានកម្មវិធីផ្តល់កិច្ចថែរក្សាសុខភាពសំរាប់តែកូនក្មេងដែលប្រហែលជាអាចមានសិទ្ធិទទួលជំនួយបាននៅថ្ងៃនេះ ។ ចូរកុំរងចាំអី ។ ដាក់ពាកសុំឥឡូវនេះទៅ

**WWW.OREGONHEALTHYKIDS.GOV** **1-877-314-5678**

ឯកសារនេះអាចត្រូវបានគេផ្តល់ជូនទៅតាមសំណើក្នុងទម្រង់ផ្សេងទៀតសំរាប់បុគ្គលដែលមានពិការភាព ។ ទម្រង់ផ្សេងទៀតអាចរួមមាន (ប៉ុន្តែមិនកំណត់ទេ)អក្សរធំ, អក្សរសំរាប់មនុស្សពិការភ្នែក, កាសែតថតសម្លេង, ការទំនាក់ទំនងតាមវ៉ិបសាយ និងទម្រង់អេឡិកត្រូនិកផ្សេងៗទៀត ដោយទូរស័ព្ទទៅលេខ 503-945-5772 សំរាប់ទម្រង់ផ្សេងៗដែលនឹងត្រូវចំពោះអ្នក ។

**Oregon Department of Human Services**
500 Summer Street NE
Salem, OR 97301
ទូរស័ព្ទលេខ: 503-945-5772
*www.oregon.gov/DHS/healthplan*

Cambodian DHS 3206 Revised 1/2010



**ចង់បានការផ្តល់ជូនកិច្ចថែរក្សាសុខភាពក្នុងតម្លៃថោក ឬដោយឥតគិតថ្លៃដែរឬទេ?**







# អ្នកប្រហែលជាអាចមានសិទ្ធិទទួលជំនួយពីគម្រោងសុខភាពរដ្ឋអូរីហ្គិន (Oregon Health Plan) បាន!

DHS | ឯករាជ្យ, សុខមាលភាព, សុវត្ថិភាព

Oregon HEALTH PLAN





## តើនរណាគេទៅដែលមានសិទ្ធិនោះ?

កម្មវិធីនៃគម្រោងសុខភាពរដ្ឋអូរីហ្គិន (OHP) ក៏រឹតស្តង់ដាផ្តល់ជូននូវកិច្ចថែរក្សាសុខភាពដោយឥតគិតថ្លៃ ឬក្នុងតម្លៃថោកសំរាប់ប្រជាពលរដ្ឋរស់នៅក្នុងរដ្ឋអូរីហ្គិនណាដែល:

- ☑ មិនមានកិច្ចធានារ៉ាប់រងសុខភាព ;
- ☑ មានអាយុពី 19 ទៅ 64 ឆ្នាំ ;
- ☑ មិនមែនជាស្ត្រីមានផ្ទៃពោះ ;
- ☑ មានប្រាក់ចំណូលទៅតាមការកំណត់ ;
- ☑ មិនបានទទួលជំនួយមេឌីឃែរ ។

ចំពោះជនណាដែលមិនមានលក្ខណៈខាងលើ ប្រហែលជាអាចទទួលបានជម្រើសនៃកិច្ចថែរក្សាសុខភាពផ្សេងទៀត ។ សូមអានផ្នែកខាងក្រោយនៃឯកសារបោះពុម្ពនេះសំរាប់ពតិមានបន្ថែម ។

## ការបើកជូនដោយមានការកំណត់

ក្រសួងសង្គមកិច្ចនៃរដ្ឋអូរីហ្គិន (DHS) គឺកំពុងតែធ្វើនូវបញ្ជីរាយឈ្មោះមនុស្សណាដែលចង់ដាក់ពាក្យសុំជំនួយពីកម្មវិធី OHP ក៏រឹតស្តង់ដា ។ អ្នកត្រូវតែចុះឈ្មោះរបស់អ្នកទៅក្នុងបញ្ជីចុះឈ្មោះបម្រុងដើម្បីមានឱកាសដាក់ពាក្យសុំជំនួយ OHP ក៏រឹតស្តង់ដា ។

ក្រសួង DHS នឹងចុចឈ្មោះជ្រើសរើសជាទូទៅចេញពីបញ្ជីឈ្មោះ ។ ប្រសិនបើឈ្មោះរបស់អ្នកត្រូវបានគេជ្រើសរើសចំហើយនោះ អញ្ចឹងក្រសួង DHS នឹងផ្ញើជូនអ្នកនូវពាក្យសុំជំនួយ OHP ក៏រឹតស្តង់ដា ។ ប្រសិនបើអ្នកដាក់ពាក្យសុំជំនួយហើយមានសិទ្ធិទទួលនោះ អ្នកនឹងត្រូវបានគេចុះឈ្មោះទៅក្នុងជំនួយ OHP ក៏រឹតស្តង់ដាហើយ ។

## OHP ក៏រឹតស្តង់ដាផ្តល់ជូន:

- សេវាទៅមើលពេទ្យ
- ថ្នាំពេទ្យតាមវេជ្ជបញ្ជា
- សេវាកម្មបំបាត់ការញៀនជាតិគីមី និងពេទ្យសុខភាពផ្លូវចិត្ត
- សេវាកម្មផ្នែកពេទ្យពេលមានកិច្ចសង្គ្រោះបន្ទាន់
- ពេទ្យធ្មេញតាមការកំណត់, សេវានៅមន្ទីរពេទ្យ និងពេទ្យភ្នែក

## ចូរកុំយឺតយ៉ាវតទៅទៀតអី — ចុះឈ្មោះថ្ងៃនេះភ្លាម!

ចូរចុះឈ្មោះទៅក្នុងបញ្ជីឱ្យបានកាន់តែឆាប់កាន់តែល្អដើម្បីឱ្យគេដាក់ឈ្មោះឱ្យទាន់នៅក្នុងការជ្រើសរើសឈ្មោះនៅពេលបន្ទាប់ទៀតនេះ ។ ចំនួនឈ្មោះដែលគេជ្រើសរើសនឹងអាស្រ័យទៅតាមទឹកប្រាក់ដែលជំនួយមានក្នុងកម្មវិធី ។ ក្រសួង DHS អាចបិទបញ្ជីឈ្មោះនៅពេលណាក៏បានដែរ ។

## ដើម្បីចាប់ផ្តើម

មានមធ្យោបាយបីយ៉ាងសំរាប់អ្នក ឬមនុស្សណាម្នាក់ដែលអ្នកស្គាល់អាចចុះឈ្មោះរបស់អ្នកទៅក្នុងបញ្ជីសុំចុះឈ្មោះបម្រុងបានៈ

- បំពេញសំណើសុំតាមអ៊ីនធឺណែតឯ www.oregon.gov/DHS/open ។
- ផ្ញើ ឬទូរសារសំណើសុំចុះឈ្មោះ ។ ពាក្យសុំអាចរកបាននៅឯគ្រប់ការិយាល័យក្រសួង DHS/AAA ទាំងអស់, ក្រសួងសុខាភិបាលប្រចាំខោនទី និងតាមមន្ទីរពេទ្យ និងគ្លីនិកភាគច្រើនដទៃទៀត ។
- ចុះឈ្មោះតាមទូរស័ព្ទ ។ ចូរទូរស័ព្ទទៅលេខ 1-800-699-9075 ឬ 711 (TTY) ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ, ពីម៉ោង 7:00 ព្រឹក ដល់ម៉ោង 6:00 ល្ងាច ។

**វាជាការងាយស្រួលណាស់, វាមានភាពយុត្តិធម៌, ចូរចុះឈ្មោះទៅក្នុងបញ្ជីទៅ!**